ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

កំពង់ផែស្វយ័តភ្នំពេញ
Phnom Penh Autonomous Port
លេខ:.០៤៣៨.. ក.ស.ភ/PPAP

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពីការប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី ១ របស់ ក.ស.ភ.

**កំពង់ផែស្វយ័តភ្នំពេញ(ក.ស.ភ.)** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ **"ក"** និងប្រភេទ **"ខ"** របស់ **ក.ស.ភ** ទាំងអស់មេត្តាជ្រាបថា÷ **ក.ស.ភ.** នឹងរៀបចំការប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី១ តាមការកំណត់ដូចខាងក្រោម៖

១. កាលបរិច្ឆេទកំណត់ទុក (Record Date)៖ **ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦**

២. កាលបរិច្ឆេទនៃការប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី១៖ **ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦**

៣. ទីកន្លែងនៃការប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី១៖ សាលប្រជុំធំជាន់ទី៣ នៃអគាររដ្ឋបាលចំណតផែកុងតឺន័រថ្មី (LM១៧) អាសយដ្ឋានស្ថិតនៅក្នុងភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

៤. កម្មវិធីនៃការប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី ១ រួមមាន÷

| | |
|---|---|
| ម៉ោង ៧:០០-៨:០០៖ | ចុះវត្តមានអ្នកចូលរួម |
| ម៉ោង ៨:៣០-៩:០០៖ | -មតិស្វាគមន៍របស់ប្រធានមហាសន្និបាត<br>-បទបង្ហាញពីលទ្ធផលការងារប្រចាំឆ្នាំ២០១៥ និងទិសដៅអនុវត្តការងារឆ្នាំ២០១៦<br>-សំណួរ-ចម្លើយ |
| ម៉ោង ៩:០០-១១:៣០៖ | ការបោះឆ្នោតជ្រើសតាំងអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន |
| ម៉ោង ១១:៣០-១២:០០៖ | មតិបិទកម្មវិធី |

ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកនាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ (កាលបរិច្ឆេទកំណត់ទុក) នឹងទទួលបានលិខិតអញ្ជើញ តាមរយៈសារអេឡិចត្រូនិកពី **ធនាគារ អេស៊ីលីដា ភីអិលស៊ី** (ភ្នាក់ងារចុះបញ្ជី ផ្ទេរមូលបត្ររបស់ **ក.ស.ភ.**) ឬអាចមកទទួលលិខិតអញ្ជើញនៅទីស្នាក់ការរបស់ **ក.ស.ភ.** ដែលមានអាសយដ្ឋាន អគាលេខ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ



ទីចាត់ការកណ្តាល: អគារលេខ ៦៤៩ តិរ:វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ
ទូរស័ព្ទ/ទូរសារ: (៨៥៥) ៤២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh
Head Office: # 649, Prah Sisowat, Sangkat Sras Chork, Khan Doun Penh, Phnom Penh
Fax/Phone: (855) 23 427 802, Email: ppapmpwt@online.com.kh / info@ppap.com.kh

រាជធានីភ្នំពេញ រៀងរាល់ថ្ងៃធ្វើការ ចាប់ពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦ ដល់ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ពីម៉ោង៨:០០ ដល់ម៉ោង១៧:០០។

បន្ទាប់ពីទទួលបានលិខិតអញ្ជើញតាមរយៈការជូនដំណឹងខាងលើ សូមភាគហ៊ុនិក មេត្តាទៅបញ្ជាក់ពីការចូលរួមនៅ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** (ភ្នាក់ងារចុះបញ្ជី ផ្ទេរមូលបត្ររបស់ **ក.ស.ភ.**) ដោយយកមកជាមួយនូវអត្តសញ្ញាណវិនិយោគិន ឬអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន **ចាប់ពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦ ដល់ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ពីម៉ោង៨:០០ ដល់ម៉ោង១៧:០០**។

- បញ្ជាក់÷ **សូមភាគហ៊ុនិកដែលអញ្ជើញមកចូលរួមក្នុងការប្រជុំមហាសន្និបាតភាគហ៊ុនិក សូមយកមកជាមួយនូវលិខិតអញ្ជើញដែលបានប្រគល់ជូន ដើម្បីចុះវត្តមានក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី១ របស់ ក.ស.ភ. និងទទួលបានបណ្ណបោះឆ្នោត។**

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមក **ធនាគារ អេស៊ីលីដា ភីអិលស៊ី** និង**កំពង់ផែស្វយ័តភ្នំពេញ** តាមអាសយដ្ឋាន និងលេខទំនាក់ទំនងដូចខាងក្រោម៖

**១. ធនាគារ អេស៊ីលីដា ភីអិលស៊ី**

-អាសយដ្ឋាន៖លេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-ទូរស័ព្ទ៖ (៨៥៥) ២៣ ៩៩៨ ៧៧៧ (ភ្ជាប់ទៅ: ៨៣១៦៧)

-ទូរសារ៖ (៨៥៥) ២៣ ៩៩៨ ៦៦៦

-ទូរស័ព្ទដៃ៖ (៨៥៥) ១៥ ៦០០ ៧៤៣

-អ៊ីម៉ែល៖ lim.an@acledabank.com.kh

**២.កំពង់ផែស្វយ័តភ្នំពេញ**

- អាសយដ្ឋាន៖ អគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរស័ព្ទដៃ៖ ០១០ ៩៤៤ ៣៨៧/០១០ ៩៤៤ ៣៦៧
- អ៊ីម៉ែល៖ ppapmpwt@online.com.kh

**ជ.គណៈកម្មការរៀបចំការប្រជុំមហាសន្និបាតភាគហ៊ុនិក**

**ប្រធាន**

**ហ៊ី_ប្រាំពីរ**

**ចម្លងជូន÷**

-ក្រសួងសាធារណការ និងដឹកជញ្ជូន

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-គណៈកម្មការមូលបត្រកម្ពុជា(គ.ម.ក)

-សមាជិកក្រុមប្រឹក្សាភិបាល ក.ស.ភ.

*"ដើម្បីជូនជ្រាប"*

-ឯកសារ-កាលប្បវត្តិ



ទីចាត់ការកណ្តាល: អគារលេខ ៦៤៩ តិរៈវិថីស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ
ទូរស័ព្ទ/ទូរសារ (៨៥៥)២៣ ៤២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh
Head Office: # 649, Prah Sisowat, Sangkat Sras Chork, Khan Doun Penh, Phnom Penh
Fax/Phone: (855) 23 427 802, Email: ppapmpwt@online.com.kh / info@ppap.com.kh